ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ**

**តាមរយៈ** លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ៖** កិច្ចប្រជុំពិភាក្សា ពិគ្រោះយោបល់បន្ត ផ្តល់ព័ត៌មានជាធាតុចូលដល់របាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ របស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ។

ថ្ងៃពុធ ៧កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០៨:៣០ នាទីរសៀល នៅសាលប្រជុំខេត្តតាកែវ នៃទីស្តីការក្រសួងមហាផ្ទៃ មានរៀបចំកិច្ចប្រជុំពិភាក្សា ពិគ្រោះយោបល់បន្ត ផ្តល់ព័ត៌មានជាធាតុចូលដល់របាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ របស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។

## I.**សមាសភាពចូលរួម**

១.ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២.ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣.ឯកឧត្តម កែវ វិសិដ្ឋ អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៤.លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

៥.លោកជំទាវ ញាណ សុចិត្រា អគ្គនាយក ក្រសួងកិច្ចការនារី

៦.ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ

៧.ឯកឧត្តម ឧត្តមសេនីយ៍ទោ ហុង វិណុល អគ្គមេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៨.ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុក ហៃសីឡា អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

៩.លោកជំទាវ សុន សុខាលីដា អគ្គនាយករង ក្រសួងយុត្តិធម៌

១០.លោកជំទាវ ឧត្តមសេនីយ៍ទោ ស៊ឹម ផាណុំ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

១១.លោក អ៊ិន សុវណ្ណធានី ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងខេត្តកណ្តាល

១២.ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាង ធារិទ្ធ អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ

១៣.លោក ឧត្តមសេនីយ៍ទោ សាន ដឹលុច អនុប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា

ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៤៣ រូប ស្រី ១០រូប ។

II. **ដំណើរកិច្ចពិភាក្សា**

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ថា កម្រងសំណួរនេះចេញដោយក្រសួងការបរទេសសហរដ្ឋអាម៉េរិក ហើយមិនមែនសម្រាប់តែកម្ពុជាតែមួយទេ គឺបានផ្តល់ទៅដល់បណ្តាប្រទេសនៅលើពិភពលោកផងដែរ ហើយខាងស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជាក៏បានជួបពិភាក្សាការងារនេះជាមួយ ឯកឧត្តមអភិសន្តិសណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ។ ចំពោះខាងសហរដ្ឋអាម៉េរិក ក៏បានលើកឡើងពាក់ព័ន្ធកម្រងសំណួរទាំងនេះថា បើយើងមិនយល់ ឬមានចម្ងល់កន្លែងណាសូមសួរបញ្ជាក់ គាត់នឹងធ្វើការបកស្រាយជូន ដូច្នេះយើងត្រូវជួបប្រជុំគ្នាដើម្បីឲ្យយល់គ្នាសិន ពីព្រោះសំណួរនីមួយៗពិតជាសំខាន់មិនអាចឆ្លើយឲ្យរួចតែខ្លួនទេ មានសំណួរមួយចំនួនពាក់ព័ន្ធក្រសួង ស្ថាប័ន អង្គភាពច្រើន ហើយអាម៉េរិកបានកំណត់យកចម្លើយត្រឹមចុងខែមករា ឆ្នាំ២០២៤ ខាងមុខនេះ ។ **លោកជំទាវ** បានលើកឡើងអំពីកាលបរិច្ឆេទការប្រគល់ទិន្នន័យប្រចាំឆ្នាំ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលខាងសហរដ្ឋអាម៉េរិកបានកំណត់យកពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ ប៉ុន្តែសម្រាប់កម្ពុជាយើងជាទូទៅគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ពេញមួយឆ្នាំ តើបញ្ហានេះយើងគិតដូចម្តេច? ត្រូវមានការឯកភាពគ្នាសិន ។ កាលពីម្សិលមិញក្រុមការងារអន្តរក្រសួងបានជួបពិភាក្សាជាមួយតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ពាក់ព័ន្ធការចេញផ្សាយអំពីតួលេខថាមានជនបរទេស ១០ម៉ឺននាក់កំពុងជាប់គាំងក្នុងប្រទេសកម្ពុជា គេបានលើកឡើងថា គឺជាការយល់ច្រឡំ បញ្ហានេះ លោកជំទាវ បានសួរទៅខាងតំណាងអង្គការសហប្រជាជាតិថា តើបានរបាយការណ៍ទាំងអស់នេះមកពីណាដើម្បីចុះផ្សាយ? ដែលការផ្សាយរបស់ UN បានធ្វើឲ្យកម្ពុជាបានបាត់បង់នូវទេសចរណ៍ សេដ្ឋកិច្ច ការវិនិយោគ សន្តិសុខសុវត្ថិភាព ចំណែកខាងតំណាងអង្គការសហប្រជាជាតិ ក៏បានទទួលថា ពិតជាមានការខុសឆ្គងចំពោះកម្ពុជាក្នុងការផ្សព្វផ្សាយព័ត៌មានទាំងអស់នេះដែលធ្វើឲ្យមានការប៉ះពាល់ដល់កិត្តិនាម សេចក្តីថ្លៃថ្នូរបស់កម្ពុជា ដោយតំណាងអង្គការសហប្រជាជាតិបានលើកឡើងថា ចាប់ពីពេលទៅ អង្គការសហប្រជាជាតិនឹងធ្វើការផ្សព្វផ្សាយនូវរៀងរាល់ ៦ខែម្តង អំពីវឌ្ឍនភាពនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់កម្ពុជា ហើយគេយកតែទិន្នន័យពីគណៈកម្មាធិការជាតិ គ.ជ.ប.ជ តែមួយទេ ដោយមិនទទួលយកការរាយការណ៍សារព័ត៌មានផ្សេងឡើយ ។ ដូច្នេះ មានន័យថាគេបានស្តាប់យើង និងមានការជឿជាក់មកលើយើងដែរ ចំណែកយើងក៏ត្រូវច្បាស់លាស់សម្រាប់ខ្លួនយើងដែរ ត្រូវមានរបាយការណ៍ប្រចាំឆមាសចុងខែមិថុនា និងខែធ្នូ ដោយភាពទទួលខុសត្រូវ ហើយយើងពិនិត្យមើលថាទិន្នន័យ ឬរបាយការណ៍ណាដែលចំណេញសម្រាប់កម្ពុជា សូមសង្ខេប និងធ្វើការដាក់បញ្ចូល តាមរយៈគណៈកម្មាធិការជាតិ យើងត្រូវមានការប្រុងប្រយ័ត្នចំពោះទិន្នន័យដែលយើងបានផ្តល់ឲ្យគេ ។ **លោកជំទាវ** ប្រធានអង្គប្រជុំ បានស្នើ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន ពិនិត្យមើលកម្រងសំណួរដែលខាងសហរដ្ឋអាម៉េរិកផ្តល់ឲ្យ សំណួរមួយណាជាការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នណា? ឬសំណួរមួយអាចមានក្រសួង ស្ថាប័នច្រើនចូលរួមឆ្លើយ សូមពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយ និងយល់អំពីសំណួរច្បាស់សិនមុនឆ្លើយ ។

**លោកជំទាវ សុន សុខាលីដា** អគ្គនាយករង ក្រសួងយុត្តិធម៌ មានមតិចូលរួមក្នុងកិច្ចប្រជុំពិភាក្សាពាក់ព័ន្ធកម្រងសំណួរដែលពាក់ព័ន្ធជាមួយក្រសួងយុត្តិធម៌ គឺអាចឆ្លើយបាន ប៉ុន្តែមានសំណួរខ្លះពាក់ព័ន្ធរួមគ្នា

ដូចជាក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាដើម ដែលចាំបាច់ត្រូវពិភាក្សាគ្នាក្នុងការឆ្លើយតបឲ្យបានស៊ីចង្វាក់គ្នា ។ បញ្ហាមួយទៀត ចំពោះសំណួរដែលមានការពាក់ព័ន្ធទៅនឹងការធ្វើវិសោធនកម្មច្បាប់ផ្សេងៗ ឬការបង្កើតបន្ថែមទៀត ក្នុងពេលបច្ចុប្បន្នកម្ពុជាមិនទាន់មានការធ្វើវិសោធនកម្មពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទេ ហើយក៏មិនមានការបង្កើតច្បាប់ ឬនីតិវិធីណាផ្សេងដែរ សម្រាប់កម្ពុជានៅតែអនុវត្តតាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨ ចំពោះចំណាត់ការពាក់ព័ន្ធរឿងក្តីជួញដូរមនុស្ស គឺយើងអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ លោកជំទាវលើកឡើងបន្តថា ចំពោះក្រសួងយុត្តិធម៌ សូមធ្វើការផ្តល់ទិន្នន័យមកពេលក្រោយ ពីព្រោះមានសារៈសំខាន់ណាស់ ដែលផ្តោតលើការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោស ដូច្នេះទិន្នន័យនេះត្រូវតែស៊ីចង្វាក់គ្នាជាមួយអ្នកអនុវត្តច្បាប់ ។ សម្រាប់ក្រសួងយុត្តិធម៌ សុំផ្ញើជូននូវរបាយការណ៍ ទិន្នន័យពាក់ព័ន្ធកម្រងសំណួររបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិកនៅចុងខែមករានេះ ពីព្រោះត្រូវការពិនិត្យឲ្យបានច្បាស់លាស់ ក៏ដូចជាត្រូវពិភាក្សាឆ្លងថ្នាក់ដឹកនាំជាមុនសិន ។ ចំពោះការកំណត់ នៃការប្រគល់របាយការណ៍ទៅឲ្យសហរដ្ឋអាម៉េរិកដោយគិតពីត្រីមាសទី២ ឆ្នាំចាស់ ដល់ត្រីមាសទី១ ឆ្នាំថ្មី យើងមិនអាចធ្វើទាន់ពេលវេលាទេ ណាមួយត្រូវបាត់ទិន្នន័យដែលយើងបានធ្វើក្នុងត្រីមាសទី១ ឆ្នាំចាស់ទៀត ពីព្រោះកម្ពុជាជាទូទៅគិតចាប់ពីខែមករា ដល់ខែធ្នូ គឺមួយឆ្នាំតាមប្រតិទិនតែម្តង បើយើងធ្វើតាមការកំណត់របស់គាត់ យើងត្រូវពិនិត្យ និងធ្វើយ៉ាងណាឲ្យទិន្នន័យស៊ីគ្នាជាមួយអ្នកអនុវត្តច្បាប់ ឬខុសគ្នាតិចតួចបំផុត យើងអាចពន្យល់គាត់អំពីរបៀបធ្វើរបាយការណ៍របស់យើង តើគាត់គិតយ៉ាងម៉េចវិញ? ឬមួយយើងគិតត្រឹមខែធ្នូ ឆ្នាំ២០២៣សិន រួចហើយចាំយើងគិតបន្តទៀត ធ្វើដូចនេះក៏ល្អដែរ ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ មានមតិលើកឡើងអំពីមាត្រាដែលសហរដ្ឋអាម៉េរិកបានយកមកអនុវត្តមាន១២មាត្រា ដែល២មាត្រាពាក់ព័ន្ធនឹងនិយមន័យ យើងគួរស្នើសុំពិនិត្យឡើងវិញ ហើយចំពោះបញ្ហានេះ ឯកឧត្តម ធ្លាប់បានលើកយកបញ្ហានេះពិភាក្សាជាមួយ **លោក បញ្ញា** រួចមកហើយ បើមានកិច្ចប្រជុំបន្តទៀតយើងគួរអញ្ជើញខាងគាត់មកចូលរួម ដើម្បីពិភាក្សាគ្នាឲ្យបានច្បាស់លាស់ ។ ឯកឧត្តមបានលើកឡើងអំពីកិច្ចសហការជាមួយសមត្ថកិច្ចបរទេស ដែលមានទីតាំង ឬការិយាល័យប្រចាំកម្ពុជា មានរឿងជាច្រើនដែលយើងបានផ្តល់ព័ត៌មានជូនទៅខាងគាត់ និងជាបញ្ហាស្មុគស្មាញដែលត្រូវអនុវត្ត ហើយប្រើពេលវេលាយូរទាំងនេះ គឺជាកិច្ចការងារដែលកម្ពុជាបានធ្វើជាមួយសមត្ថកិច្ចបរទេស តើករណីនេះយើងអាចដាក់បញ្ចូលក្នុងទិន្នន័យនេះបានទេ? ទាក់ទងនឹងពេស្យាចារ និងមានករណីជាច្រើនទៀត ។ ចំពោះការឆ្លើយសំណួររបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ក្រុមអនុវត្តច្បាប់ មានមន្ត្រីជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជំនាញ នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលបានធ្វើរឿងនេះដែរ ត្រូវពិភាក្សាផ្ទៀងផ្ទាត់ឲ្យត្រូវគ្នាចំពោះទិន្នន័យទាំងពីរ ទើបធ្វើការឆ្លើយតបត្រូវនឹងអ្វីដែលគេចង់បាន ។ មួយទៀត យើងគួរសុំយោបល់ពីអ្នកឯកទេសការងាររបាយការណ៍ ដើម្បីដាក់ឲ្យចំគោលដៅ បើដូចរាល់ឆ្នាំហាក់ដូចជារបាយការណ៍យើងគ្មានតម្លៃ ចង់ដឹងថាគាត់ចង់បានអ្វី ងាយស្រួលយើងត្រៀមខ្លួន និងតម្រូវតាមការចង់បានរបស់គាត់ ពីព្រោះច្បាប់ នៃប្រទេសនីមួយៗមិនដូចគ្នា ហើយគាត់ក៏មិនបានយកពិធីសារប៉ាឡឺម៉ូមកប្រើដែរ ចំណែកច្បាប់ប្រទេសថៃក៏មិនដូចយើងដែរ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានប្រសាសន៍ពាក់ព័ន្ធការលើកឡើងរបស់ ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គស្នងការរងនគរបាលជាតិ ទាក់ទងទៅនឹងមាត្រាទាំង១២ ដែលបានដាក់ឲ្យអនុវត្ត ដោយលោកជំទាវ បានលើកឡើងថា មានភាពប្រឈមពីរ ទី១.ភាពវល់របស់យើង គឺយើងបានធ្វើការងារនេះយ៉ាងច្រើន ប៉ុន្តែគេចង់បានអ្វី

ដែលជាក់លាក់ហើយខ្លី ងាយយល់ ក៏អាចជាវិធីសាស្ត្រ នៃសេចក្តីរាយការណ៍ដើម្បីកុំឲ្យបានគុណសម្បត្តិកិច្ចខិតខំប្រឹងប្រែង ដូច្នេះត្រូវមានការឯកភាពគ្នា រវាងក្រុមការងារយុត្តិធម៌ព្រហ្មទណ្ឌ ដោយចាប់ពីអ្នកប្រតិបត្តិការរហូតដល់ដំណាក់កាលផ្តន្ទាទោស ធ្វើយ៉ាងណាឲ្យមានទិន្នន័យស៊ីគ្នា ដូច្នេះខាងក្រសួងយុត្តិធម៌ និងអ្នកអនុវត្តច្បាប់ រួមមាននាយកដ្ឋានជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចជាកងរាជអាវុធហត្ថលើផ្ទៃប្រទេសផងដែរ និងត្រូវជជែក ពិភាក្សាគ្នាដោយទៀតឲ្យស៊ីចង្វាក់ជៀសវាងមានការឆ្លើយផ្សេងគ្នា ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាង ធារិទ្ធ** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ មានមតិចូលរួមដោយលើកឡើងថា ពាក់ព័ន្ធការផ្តល់របាយការណ៍ ទិន្នន័យសម្រាប់ការឆ្លើយតបជាក្រសួងការបរទេសសហរដ្ឋអាម៉េរិក ចំពោះក្រសួងយុត្តិធម៌ និងមន្ត្រីអនុវត្តច្បាប់ ដើម្បីមានភាពងាយស្រួលក្នុងការរាយការណ៍ ត្រូវគិតលើចំណុច៤ ដែលជាចំណុចខ្លាំងធ្លាប់បានអនុវត្តលើការងារប្រឆាំងការសម្អាតប្រាក់ ចំណុចទី១.ត្រូវយកចិត្តទុកដាក់ចំពោះករណីដែលបានបញ្ជូនទៅតុលាការ រាប់ទាំងនគរបាល និងអាវុធហត្ថ ហើយបើមានការចោទប្រកាន់ ឬមិនមានការចោទប្រកាន់ ឬស្ថិតតាមការស្រាវជ្រាវចាប់បន្ត យើងអាចធ្វើការពន្យល់គេបាន ។ ក្រុមការងារយើងបានត្រៀមរួចរាល់ហើយសម្រាប់ធ្វើការឆ្លើយតបជាមួយសំណួរពាក់ព័ន្ធការងារជួញដូរមនុស្ស និងបទល្មើសតាមប្រព័ន្ធអនឡាញ គិតចាប់ពីដើមឆ្នាំ២០២៣ បូកបន្ថែម ត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ មានចំនួន ១៥ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ៣៣នាក់ បានចោទប្រកាន់ ៥ករណី ជនសង្ស័យ១៨នាក់ បានផ្តន្ទាទោស ៥ករណី ទាំងនេះគឺជារបាយការណ៍សង្ខេបរបស់ក្រុមការងារ មានបញ្ជីទិន្នន័យច្បាស់លាស់ចាប់តាំងពីដើមរហូតដល់បិទករណី ។ ចំណុចទី២. ត្រូវគិតនៅក្នុងកន្សោម នៃធាតុចូលដែលជាបទល្មើសជួញដូរមនុស្ស ក្រៅពីករណីជួញដូរមនុស្ស កុំយកមកដាក់បញ្ចូល ។ ចំណុចទី៣.ចំពោះករណីនីមួយៗត្រូវមានបញ្ជីច្បាស់លាស់ តារាងទទឹងក៏ដោយ តារាងបញ្ឈក៏ដោយត្រូវមានគ្រប់ដំណាក់កាលចាប់ពីការបង្ក្រាបរហូតដល់ការចោទប្រកាន់ ។ ចំណុចទី៤.ត្រូវកំណត់ឲ្យបានច្បាស់ កុំធ្វើហើយធ្វើទៀត បើមានការខុសគ្នាតែមួយថ្ងៃ គឺខុសតួលេខនាំឲ្យពិបាកក្នុងការបូកសរុបតាមដានសាច់រឿង ។ ចំពោះការប្រគល់របាយការណ៍ ទិន្នន័យបើសហរដ្ឋអាម៉ារិកគេចង់បានពីត្រីមាសទី២ឆ្នាំ២០២៣ ដល់ត្រីមាសទី១ឆ្នាំ២០២៤ គឺមិនមែនជាបញ្ហាទេ បើយើងគ្រប់គ្រងបានច្បាស់លាស់ ។

បន្ទាប់ពីអង្គប្រជុំបានធ្វើការពិភាក្សា អំពីចំណុចសំខាន់ៗមួយចំនួនពាក់ព័ន្ធកម្រងសំណួររបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួចមក អង្គប្រជុំបានពិនិត្យមើលខ្លឹមសារ នៃសំណួរនីមួយៗ និងបានធ្វើការបែងចែកទៅតាមបណ្តាក្រសួង ស្ថាប័ន អង្គភាពដើម្បីទទួលខុសត្រូវក្នុងការឆ្លើយតប ក៏ដូចជាផ្តល់នូវរបាយការណ៍ ទិន្នន័យតាមខ្លឹមសារសំណួរ ។

## III.លទ្ធផលកិច្ចប្រជុំពិភាក្សា

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍បូកសរុបលទ្ធផលកិច្ចប្រជុំពិភាក្សា ពិគ្រោះយោបល់បន្ត ដើម្បីផ្តល់ព័ត៌មានជាធាតុចូលដល់របាយការណ៍ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ របស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ដោយ លោកជំទាវ បានលើកឡើងថា កិច្ចប្រជុំក្នុងថ្ងៃនេះ គឺយើងទទួលបានធាតុចូលច្រើនទោះបីមិនទាន់បានគ្រប់ជ្រុងជ្រោយក៏ដោយ យើងក៏បានយល់គ្នាច្រើនផងដែរ ដូច្នេះ សូមក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធដែលទទួលខុសត្រូវក្នុងការ

ក្នុងការឆ្លើយតបសំណួរ ក៏ដូចជាការផ្តល់របាយការណ៍ ទិន្នន័យពិនិត្យឡើងវិញចំពោះសំណួរ និងសូមផ្ញើចម្លើយមក គណៈកម្មាធិការជាតិ ត្រឹមសប្តាហ៍ក្រោយ ហើយចុងខែមករា យើងនឹងជួបប្រជុំគ្នាដើម្បីបញ្ចប់ដើម្បីផ្តល់ជូនខាង សហរដ្ឋអាម៉េរិក ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានប្រសាសន៍ថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ដែលបានចំណាយពេលចូលរួមក្នុងកិច្ចប្រជុំពិភាក្សា ពិគ្រោះយោបល់ដើម្បីឆ្លើយតបទៅនឹងសំណួររបស់សហរដ្ឋអាម៉េរិក ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសូមជូនពរជួបតែសេចក្តីសុខ សុវត្ថិភាព និងទទួលបានជោគជ័យគ្រប់ភារកិច្ច ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុ ប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃសុក្រ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក សៅ ស៊ីនួន

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃចន្ទ ១១រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់

បាន ឃើញ
01/02/24